## ជំពូកទី ១៤

# ត្រៀមកុមារសំរាប់ចូលសាលារៀន (សាលាមត្តេយ្យ និង សាលាបឋមសិក្សា)

នៅក្នុងសហគមន៍មួយចំនួនមានកន្លែងថែទាំកុមារតូចៗ នៅខណៈពេលដែលក្រុមគ្រួសាររបស់ពួកគេធ្វើការងារ ។ ជាញឹកញាប់កន្លែងទាំងនេះហៅថា សាលាមត្តេយ្យ, មជ្ឈមណ្ឌលគាំពារកុមារពេលថ្ងៃ ឬ មជ្ឈមណ្ឌលថែទាំកុមារ ។

កុមារពិការភ្នែក ឬ កុមារដែលមិនអាចមើលឃើញច្បាស់អាចទៅសាលាមត្តេយ្យជាមួយក្មេងៗដទៃ ។ ហើយនៅពេលកូនអ្នកធំល្មមអាចចូលរៀន នាងគួរទៅសាលារៀនដូចកុមារឯទៀតៗដែលមានអាយុស្រករនាងអញ្ចឹងដែរ ។ ដើម្បីធ្វើឱ្យបទពិសោធន៏ទាំងនេះទទួលបានជោគជ័យដោយរីករាយអ្នកអាច :-

- ជួយកូនឱ្យចេះត្រៀមខ្លួនសំរាប់ទៅរៀននៅសាលាមត្តេយ្យ ឬ សាលារៀន ។
- ជួយគ្រូបង្រៀននៅសាលាមត្តេយ្យ ឬ សាលារៀនត្រៀមខ្លួនដើម្បីឱ្យពួកគាត់អាចជួយដល់កូនរបស់អ្នក ។

## ការជួយកូនឱ្យចេះត្រៀមខ្លួនដើម្បីទៅរៀននៅសាលាមត្តេយ្យ និង សាលារៀន

### ➤ វិធីរៀនលេងកំសាន្តរបស់កុមារជាក្រុម

នៅសាលារៀន កូនរបស់អ្នកនឹងលេងកំសាន្តយ៉ាងច្រើនជាមួយកុមារដទៃ ។ នៅអំឡុងឆ្នាំ មុនពេលនាងគ្រប់អាយុទៅសាលារៀន អ្នកអាចជួយកូនឱ្យចេះត្រៀមខ្លួនដោយការលើកទឹកចិត្តនាងឱ្យលេងកំសាន្តជាមួយក្មេងៗឯទៀត និងជួយកុមារឯទៀតឱ្យចេះលេងកំសាន្តជាមួយកូនរបស់អ្នក ។

បើសិនជាកូនរបស់អ្នកមានបទពិសោធន៍លេងកំសាន្ត ជាមួយមិត្តភក្តិ មុនពេលនាងចាប់ផ្តើមចូលសាលារៀន នាងអាចមានការងាយស្រួលថែមទៀត ក្នុងការចេះ បង្កើតមិត្តភក្តិថ្មីៗ ពេលនាងទៅសាលារៀន។



**➤ វិធីស្វែងឱ្យដឹងអំពីការថែទាំកុមារមានលក្ខណៈបែបណាខ្លះនៅសាលាមត្តេយ្យ ឬ សាលារៀន?**

បើកូនរបស់អ្នកមិនបានចំណាយពេលច្រើនជាមួយកុមារធំៗ នាងអាចមិនយល់អំពីអ្វីៗដែលនឹងកើតឡើងនៅឯមជ្ឈមណ្ឌលគាំពារកុមារ ឬ សាលារៀន ពីព្រោះការស្តាប់ឮរឿងរ៉ាវទាំងឡាយអំពីសាលារៀន ជាវិធីដែលកុមារជាច្រើនបានរៀនសូត្រអំពីវា។ កុមារពិការភ្នែក ឬ កុមារដែលមិនអាចមើលឃើញច្បាស់ប្រហែលខ្លាចឃ្លាតឆ្ងាយពីក្រុមគ្រួសាររបស់នាងអំឡុងការចំណាយពេល 2-3 ម៉ោងនៅសាលារៀន។ ដើម្បីជួយនាងឱ្យយល់អំពីមណ្ឌលគាំពារកុមារ ឬ សាលារៀន :-

ចូរប្រាប់នាងនូវករណីដែលគួរឱ្យរំភើបមួយចំនួនអំពីមណ្ឌលគាំពារកុមារ ឬ សាលារៀន។




ស្នើសុំឱ្យក្មេងធំជាងកូនរបស់អ្នកឱ្យលេងកំសាន្តអំពី "សាលារៀន" ជាមួយកូនរបស់អ្នក។




**➤ វិធីស្វែងយល់អំពីអាគារនៃសាលារៀន ឬ អាគារនៃមជ្ឈមណ្ឌលគាំពារកុមារ**

បើសិនជាកូនអ្នកបានទៅឃើញសាលារៀនមុនពេលនាងចូលរៀន ដើម្បីឱ្យស្គាល់ពីបរិវេណនិងទីតាំងសាលារៀន ក៏ដូចជាថ្នាក់រៀនរបស់នាង និងដឹងពីរបៀបដើរនៅក្នុងបរិវេណសាលារៀនដោយខ្លួនឯង នោះនៅថ្ងៃចូលរៀនដំបូងនាងនឹងមានអារម្មណ៍កាន់តែស្រួលក្នុងចិត្ត។ ចូរព្យាយាមទៅជួបគ្រូបង្រៀន ហើយដើរអង្កេតមើលសាលារៀននៅពេលក្មេងៗដទៃអវត្តមានពីទីនោះ។



## ការជួយសាលារៀនត្រៀមរៀបចំសំរាប់កូនរបស់អ្នក

### ➤ វិធីជួយគ្រូបង្រៀនឱ្យយល់អំពីកូនរបស់អ្នក

គ្រូបង្រៀនម្នាក់ដែលមិនធ្លាប់ធ្វើការជាមួយកុមារពិការភ្នែក ឬ កុមារដែលមិនអាចមើលឃើញច្បាស់ ប្រហែលជាមិនប្រាកដក្នុងចិត្តអំពីរបៀបបង្រៀនកូនរបស់អ្នក ។ អ្នកស្គាល់កូនខ្លួនឯងច្បាស់ជាងនរណាៗទាំងអស់ ហើយអ្នកមានអ្វីៗជាច្រើនដែលអាចចែករំលែកជាមួយគ្រូបង្រៀន ។ នេះជាគំនិតមួយចំនួនដែលអ្នកអាចជម្រាបដល់គ្រូបង្រៀន :-

- ចូរជម្រាបដល់គ្រូបង្រៀនអំពីបំណិន និង លទ្ធភាពរបស់កូន ។
- ចូរបង្ហាញគ្រូបង្រៀនពីរបៀបជួយកូនរបស់អ្នកបំលាស់ទីតាំងនៅក្នុងថ្នាក់ និងបរិវេណសាលារៀន ។
- បើសិនជាកូនរបស់អ្នកអាចមើលឃើញតិចតួច ចូរពន្យល់គ្រូបង្រៀនពីអ្វីដែលកូនអាចមើលឃើញ និងរបៀបដែលកូនប្រើគំហើញរបស់នាង ។
- ចូររំលឹកគ្រូបង្រៀនថា កូនរបស់អ្នកមិនអាចមើលឃើញកាយវិការ ឬ ការសំដែងទឹកមុខឡើយ ដូច្នេះការបង្រៀនត្រូវធ្វើតាមរយៈការនិយាយឱ្យច្បាស់ៗ ។
- ចូរពិភាក្សាអំពីករណីលំបាកៗដែលកូនរបស់អ្នកកំពុងប្រឈមមុខ ។
- ចូរចែករំលែកព័ត៌មានអំពីភាពពិការភ្នែក និងរបៀបដែលវាប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ ។




ផ្នែកស្តីពីរបៀបដែលសមាជិកសហគមន៍អាចជួយ គឺចាប់ផ្តើមនៅទំព័រ 126 មានផ្តល់យោបល់ដ៏មានប្រយោជន៍សំរាប់គ្រូបង្រៀនផងដែរ ។ ជាពិសេសអ្នកអាចចែករំលែកគំនិតខ្លះៗចំពោះការជួយកុមារឱ្យកាន់តែយល់អំពីភាពពិការភ្នែក និងវិធីទាំងឡាយដើម្បីបញ្ចូលកុមារដែលមិនអាចមើលឃើញច្បាស់ទៅក្នុងការលេងកំសាន្តរបស់កុមារ ។

### ➤ វិធីត្រៀមរៀបចំថ្នាក់រៀនសំរាប់កូនរបស់អ្នក

ចូរនិយាយជាមួយគ្រូបង្រៀនអំពីថ្នាក់រៀន និងសង្កេតរកមើលវិធីងាយៗដើម្បីធ្វើឱ្យបន្ទប់រៀនឱ្យកាន់តែមានសុវត្ថិភាព និងកាន់តែស្រួលសំរាប់កូនរបស់អ្នក ។ អ្នកអាចមានបំណងដើម្បី :-

- ពន្យល់ថាក្មេងពិការភ្នែកអាចដើរបុក ឬ ទង្គិចវត្ថុ និងវិធីជួយរក្សាទ្វារឱ្យបើកចំហរ ឬ បិទទាំងស្រុង ។
- ពន្យល់ពីសារៈសំខាន់នៃការទុកដាក់វត្ថុនៅកន្លែងដដែល ធ្វើដូច្នេះកូនរបស់អ្នកអាចដើរក្នុងបរិវេណបន្ទប់រៀនយ៉ាងទុកចិត្ត ហើយមិនខ្វល់ខ្វាយ ។
- ជាការប្រសើរ បើសិនជាមានការសំរេចចិត្តឱ្យកូនរបស់អ្នកអង្គុយនៅតុជួរមុខក្នុងថ្នាក់ក្បែរគ្រូបង្រៀន ។




**បើកូនរបស់អ្នកអាចមើលឃើញតួអក្សរ គ្រូបង្រៀនគួរតែសរសេរអក្សរឱ្យជិតធំៗលើក្តារខៀន និងត្រួតពិនិត្យឱ្យបានញឹកញាប់បើកូនរបស់អ្នកអាចមើលឃើញតួអក្សរទាំងនោះ។**

### ការត្រៀមរៀបចំដើម្បីរៀនអាន និង រៀនសរសេរ

បើសិនជាកូនរបស់អ្នកអាចមើលឃើញតិចតួច ចូរព្យាយាមស្វែងរកឱ្យឃើញអ្វីមួយដែលអាចជួយឱ្យកូនមើលឃើញអក្សរ ។ បើសិនជាកូនរបស់អ្នកអាចមើលឃើញតួអក្សរ កូនប្រហែលជាអាចអានដោយប្រើ :-



**ពាក់វ៉ែនតា**



**ការប្រើកែវពង្រីក (កែវដែលអាចធ្វើឱ្យតួអក្សរតូចៗ មើលឃើញធំៗ)**




**ការអានសៀវភៅដែលបោះពុម្ពអក្សរធំៗ ធ្វើដូច្នេះកុមារអាចមើលឃើញតួអក្សរបានងាយស្រួល។**

បើសិនជាកូនរបស់អ្នកនៅតែមានបញ្ហាក្នុងការអានអក្សរនៅសាលារៀន អ្នកអាច :-

- ស្នើឱ្យនរណាម្នាក់អានសៀវភៅ និងមេរៀនឱ្យឮៗដល់កូនរបស់អ្នក ។
- ស្នើឱ្យនរណាម្នាក់អានសៀវភៅថតសម្លេងក្នុងកាសែតម៉ាញេ ធ្វើដូច្នេះកូនរបស់អ្នកអាចស្តាប់ពីអ្វីៗនៅក្នុងសៀវភៅនៅពេលក្រោយ ។
- ចូរគិតពិចារណាបង្រៀនអក្សរប្រៃយ៍ដល់កូនរបស់អ្នក ( អានទំព័រ 139) ។ ប្រការនេះប្រហែលជាជំរើសល្អបំផុត បើសិនជាគំហើញរបស់កូនអ្នកទំនងជាដុនដាបទៅៗ ។

## ការរៀនអាននិងសរសេរអក្សរប្រៃយ៍



បើកូនរបស់អ្នកមិនអាចមើលឃើញអក្សរ ឬ ពិការភ្នែក គ្រូដែលបានហាត់រៀនបំណិនអំពីតម្រូវការពិសេសអាចបង្រៀនកុមារពិការភ្នែកឱ្យចេះប្រើការអាននិងសរសេរប្រព័ន្ធមួយហៅថា "ប្រៃយ៍"។ ប្រៃយ៍អាចមើលទៅពិបាកដោយសារតែវាថ្មីចំពោះអ្នក។ កុមារ និង មនុស្សធំស្ទើរតែទាំងអស់អាចរៀនប្រៃយ៍បានយ៉ាងងាយស្រួល។

**ប្រហែលជាមានសាលារៀនពិសេស ឬ ថ្នាក់រៀនពិសេសសំរាប់កុមារពិការភ្នែក និងមានគ្រូបង្រៀនដែលនឹងបង្រៀនប្រៃយ៍ដល់កុមារ។**

ដើម្បីចេះអានប្រៃយ៍ កុមារបង្អួសចុងម្រាមដៃលើផ្ទៃកំពីកកំពកដែលតំណាងឱ្យតួអក្សរនៃព្យញ្ជនៈ។ "តួអក្សរ" ទាំងនេះត្រូវបានបញ្ចូលរួមគ្នាដើម្បីបង្កើតជាពាក្យបែបនេះ។



**ឆ្កែ**

**ដើម្បីសរសេរប្រៃយ៍ កុមារអាចប្រើឧបករណ៍ប្លែកៗគ្នា។ ឧបករណ៍ធម្មតាសំរាប់សរសេរប្រៃយ៍គឺបន្ទាត់ដែកមានប្រហោងល្អិតៗសំរាប់ចាក់តួអក្សរ និង ដែកចារ (ចាក់ចូលប្រហោងបន្ទាត់)។**





កុមារសរសេរជាមួយបន្ទាត់ដែកមានប្រហោងល្អិតៗ និងដែកចារដោយការចាក់ចុងដែកចារតាមប្រហោងបន្ទាត់ដែកទៅលើក្រដាសក្រាស់។ បន្ទាប់មកគេអាចត្រឡប់ក្រដាសឱ្យផ្ទៃកកំពីកកំពកមកលើ ដើម្បីអានដោយប្រើចុងម្រាមដៃរបស់គេ។

កុមារនឹងរៀនអក្សរប្រៃយ៍កាន់តែងាយស្រួល បើសិនជាកូនមានម្រាមដៃមាំមួន ហើយងាយបត់បែន។ សំរាប់ព័ត៌មានបន្ថែម ចូរអានទំព័រ 98។

## សាលារៀនសំខាន់ណាស់សំរាប់កុមារគ្រប់រូប

សាលារៀនសំខាន់ណាស់សំរាប់កុមារពិការភ្នែក ដោយសារតែកុមារពិការភ្នែកជារឿយៗមិនសូវមានឱកាសដូច កុមារដែលអាចមើលឃើញ ។ កុមារពិការភ្នែកអាចទៅសាលារៀន ហើយរៀនយ៉ាងច្រើន រួមទាំងបំណិនទាំងឡាយដែល ពួកគេនឹងត្រូវការដើម្បីរកចំណូលគាំទ្រការរស់នៅនាពេលអនាគត ។ នៅកន្លែងខ្លះ កុមារពិការភ្នែកអាចទៅសាលារៀន ពិសេសសំរាប់កុមារពិការភ្នែក ។ សាលារៀនរដ្ឋមួយចំនួននៅ ក្នុងស្រុកភូមិអាចមានកម្មវិធីពិសេសសំរាប់កុមារពិការភ្នែក ។ ជាមួយការជួយជ្រោមជ្រែងបន្ថែម កុមារពិការភ្នែកអាចធ្វើបានល្អនៅក្នុងថ្នាក់រៀនជាមួយកុមារដែលអាចមើលឃើញ ។

អង្គការគ្រួសារថ្មីនៅប្រទេសខ្មែរយើងមានសាលារៀនពិសេសសំរាប់កុមារពិការភ្នែក, បង្រៀនជាប្រៃយ៍ និងបាន សហការបង្កើតថ្នាក់រៀនពិសេសក្នុងសាលារដ្ឋទូទាំងប្រទេសកម្ពុជា ដែលកុមារគ្រប់រូបអាចចូលរៀន ។ ចូរមើលអាស័យដ្ឋាន ទាក់ទងអង្គការនេះនៅទំព័រខាងក្រោយក្នុងសៀវភៅនេះ ស្តីពីធនធាន និង អង្គការមួយចំនួនដែលធ្វើការសំរាប់វិស័យពិការភាពនៅក្នុងស្រុកខ្មែរ ។

